វិទ្យាស្ថានបើកទូលាយ
Open Institute

## បទបង្ហាញស្តីពី

# ការផ្លាស់ប្តូរពី Microsoft Office មក OpenOffice និងយូនីកូដខ្មែរ

# សេចក្តីផ្តើម

- **សុខ សុភា**
- គ្រូបង្គោលសម្រាប់កម្មវិធីស្ត្រីនៃអង្គការវិទ្យាស្ថានបើកទូលាយ
- អ្នកបកប្រែកម្មវិធីកុំព្យូទ័រសម្រាប់កម្មវិធីខ្មែរអូអេស (KhmerOS) ក្នុងគម្រោង SPICE នៃអង្គការវិទ្យាស្ថានបើកទូលាយ
- www.open.org.kh/spice
- 012 56 57 90
- sophea@open.org.kh ឬ sksophea@gmail.com

# ហេតុអ្វីត្រូវប្តូរពី Microsoft Office មក OpenOffice ?





# លក្ខណៈរបស់ OpenOffice

- មានពីរភាសាត្រូវតាមការជ្រើសរើសរបស់អ្នក






# ការប្រៀបធៀបកម្មវិធី

កម្មវិធីការិយាល័យខ្មែរ OpenOffice.org មានលក្ខណៈស្រដៀងគ្នាទៅនឹងកម្មវិធីរបស់ Microsoft Office ។ តារាងខាងក្រោមនឹងធ្វើការប្រៀបធៀបសមាសភាគដែលមានលក្ខណៈស្រដៀងគ្នាក្នុងកម្មវិធីការិយាល័យទាំងពីរនេះ ៖

| មុខងារ | OpenOffice | Microsoft Office |
|---|---|---|
| ឯកសារអត្ថបទ | ស្លឹករឹត (OpenOffice.org Writer) | Microsoft Word |
| សៀវភៅបញ្ជី | នព្វន្ត (OpenOffice.org Calc) | Microsoft Excel |
| ការបង្ហាញ | ពិព័រណ៌ (OpenOffice.org Impress) | Microsoft PowerPoint |
| មូលដ្ឋានទិន្នន័យ | OpenOffice.org Base | Microsoft Access |
| គំនូរ | OpenOffice.org Draw | គ្មាន |
| និពន្ធរូបមន្ត | OpenOffice.org Math | Microsoft Equation |

# លក្ខណៈកម្មវិធីកុំព្យូទ័រភាសាខ្មែរ

កម្មវិធីកុំព្យូទ័រភាសាខ្មែរ គឺជា កម្មវិធីបកប្រែពីកម្មវិធីកូដចំហ (Open Source Software) ដែលអ្នកប្រើមិនចាំបាច់ទិញអាជ្ញាប័ណ្ណ (License) ឬសិទ្ធិប្រើប្រាស់ទេ ហើយវាមានលក្ខណៈពិសេសជាច្រើនដូចជា ៖

- មិនចាំបាច់បង់ថ្លៃអាជ្ញាប័ណ្ណ សន្សំសំចៃផ្នែកសេដ្ឋកិច្ច
- កាត់បន្ថយពេលវេលា និងការចំណាយផ្សេងៗ ទៅលើការសិក្សាភាសាអង់គ្លេស និងការសិក្សាជាថ្មីនៅពេលកំណែក្រោយៗចេញ
- មានភាសាខ្មែរពេញលេញក្នុងកម្មវិធី ធ្វើឲ្យងាយយល់
- ជាកម្មវិធីឥតគិតថ្លៃ ងាយស្រួលប្រើ
- អាចតម្រៀបអក្សរខ្មែរបានតាមលំដាប់អក្ខរក្រម
- អាចពិនិត្យអក្ខរាវិរុទ្ធ និងសទិសន័យនៃពាក្យខ្មែរបាន

# កម្មវិធីកុំព្យូទ័រដែលយើងបានបកប្រែ

- Open SUSE
- Ubuntu
- Open Office (កម្មវិធីការិយាល័យខ្មែរ)
- Firefox ភាសាខ្មែរ (មេខលា)
- Thunderbird (មយូរា)
- VLC កម្មវិធីមេឡៀ
- Gimp កម្មវិធីរចនារូបភាព
- Gnome និង KDE (User Interface សម្រាប់ Linux)
- Drupal កម្មវិធីរចនាគេហទំព័រ

# របៀបដំឡើងកម្មវិធីកុំព្យូទ័រភាសាខ្មែរ

- ដាក់ស៊ីឌីកម្មវិធីកុំព្យូទ័រភាសាខ្មែរចូលក្នុងជ្រាយស៊ីឌី ឬឌីវីឌីរបស់អ្នក
- ចុចលើ **ទំព័រដើម** រួចប៊ូតុង **ដំឡើង** ប្រសិនបើអ្នកចង់ដំឡើងកម្មវិធីទាំងអស់ ឬជ្រើសកម្មវិធីណាមួយដែលអ្នកចង់ដំឡើងក៏បាន (យូនីកូដខ្មែរ កម្មវិធីការិយាល័យខ្មែរ...) រួចប៊ូតុង **ដំឡើង** ។






# របៀបដំឡើងកម្មវិធីពិនិត្យអក្ខរាវិរុទ្ធខ្មែរ

- នៅក្នុងផ្ទាំងដែលបានលេចឡើងចុចប៊ូតុង **រុករកលើស៊ីឌី**
- បន្ទាប់មកបង្អួចរុករកនឹងលេចឡើង
- ចុចទ្វេដងលើថត Khmer-Spellchecker-v1.0.2
- បន្ទាប់មកចុចទ្វេដងលើ km_spellchecker_OOo30_V_1.0.2
- រួចចុចប៊ូតុង **យល់ព្រម**
- បន្ទាប់មកចុចប៊ូតុង **បិទ**

# កម្មវិធីស្លឹករឹត និងរបៀបវាយយូនីកូដខ្មែរ

# OpenOffice.org Writer & Khmer Unicode






# គោលបំណង

នៅក្នុងបទបង្ហាញនេះ អ្នកនឹងសិក្សាអំពី ៖

- ការប្រើឧបករណ៍ និងម៉ឺនុយសំខាន់ៗនៅក្នុងកម្មវិធីស្លឹករឹត
- របៀបវាយព្យញ្ជនៈ ស្រៈ និងសញ្ញផ្សេងៗ
- របៀបវាយពាក្យខ្មែរ (ព្យញ្ជនៈ + ស្រៈ)
- របៀបវាយជើងព្យញ្ជនៈ (សញ្ញាដាក់ជើង ្ + ព្យញ្ជនៈ)
- ការប្រើប្រាស់ត្រីសព្ទ ( ៊) និងមូសិកទន្ត ( ៉)
- ការប្រើប្រាស់សញ្ញលើ ៍ ៌ ៏ ៎ ័ ់
- ស្វែងយល់អំពីចន្លោះមិនឃើញ ចន្លោះភ្ជាប់ និងដកឃ្លា

# តើយូនីកូដខ្មែរមានប្រយោជន៍អ្វីខ្លះ?

- ធ្វើឲ្យកូនខ្មែរស្គាល់ពីរបៀបប្រកបអក្សរខ្មែរ
- មានលក្ខណៈងាយស្រួលក្នុងការវាយ (វាយតាមប្រកប)
- មានព្យញ្ជនៈ និងស្រៈពេញលេញនៅលើប្លង់ក្តារចុច
- មានពុម្ពអក្សរខ្មែរជាច្រើនតាមតម្រូវការ
- អាចបង្ហាញ និងស្វែងរកព័ត៌មានលើអ៊ីនធឺណិតជាភាសាខ្មែរបាន
- អាចទំនាក់ទំនងគ្នាជាភាសាខ្មែរបានតាមរយៈអ៊ីមែល និងការជជែកកម្សាន្ត

# យូនីកូដខ្មែរ

**យូនីកូដខ្មែរ** គឺជាស្តង់ដារអន្តរជាតិថ្មីមួយសម្រាប់ភាសាខ្មែរ ដែលផ្តល់លេខកូដជាក់លាក់សម្រាប់ព្យញ្ជនៈ ស្រៈ និងសញ្ញា ភាសាខ្មែរទាំងអស់ ដើម្បីប្រើប្រាស់ក្នុងកុំព្យូទ័រ ។ ដូច្នេះ គ្រប់ពុម្ពអក្សរយូនីកូដខ្មែរ ដែលអ្នកសរសេរក្នុងកម្មវិធី ឬប្រព័ន្ធប្រតិបត្តិការផ្សេងៗ ក៏អាចមើលឃើញពុម្ពអក្សរនោះបានធម្មតាដែរ ទោះបីជាកុំព្យូទ័រអ្នកមានពុម្ពអក្សរយូនីកូដខ្មែរផ្សេងគ្នាក៏ដោយ គឺគ្រាន់តែខុសទ្រង់ទ្រាយតែប៉ុណ្ណោះ តែការបម្លែងកូដ គឺដូចគ្នា ។

ក = 1780

ខ = 17FF

....

# បើកកម្មវិធី

- ចុច Start ->Programs ->OpenOffice.org 3.3 ->OpenOffice.org Writer



# ប្តូរក្តារចុចជាក្តារចុចយូនីកូដខ្មែរ

ចំណាំ ៖ ដើម្បីវាយអក្សរខ្មែរ អ្នកត្រូវ**ប្តូរក្តារចុច**មកជាក្តារចុចយូនីកូដខ្មែរ (CA)។




- ចុច *ជំនួស + ប្តូរ (Alt + Shift)*

# របៀបវាយយូនីកូដខ្មែរ (៥)

ចំពោះវីនដូវីស្តា (Windows Vista និង Windows 7) ក្តារចុចយូនីកូដខ្មែរសម្គាល់ដោយ KH - Khmer (Cambodia) ។







ចំណាំ ៖ ដើម្បីអាចប្រើប្រាស់យូនីកូដខ្មែរក្នុងកុំព្យូទ័របាន អ្នកចាំបាច់ត្រូវដំឡើងយូនីកូដខ្មែរ ហើយប្រព័ន្ធប្រតិបត្តិការវីនដូ (Windows) ដែលគាំទ្រយូនីកូដខ្មែរ គឺត្រូវមានកំណែចាប់ពី Microsoft Windows 2000 ឡើងទៅ ។

# ប្រៀបធៀបយូនីកូដខ្មែរ និងពុម្ពអក្សរចាស់

| យូនីកូដខ្មែរ | ពុម្ពអក្សរចាស់ (Limon,...) |
|---|---|

- មានព្យញ្ជនៈ និងស្រៈពេញលេញលើប្លង់ក្ដារចុច
- វាយតាមប្រកប

  រ + ◌ៀ + ន -> រៀន

- ពុំមានស្រៈពេញលេញលើប្លង់ក្ដារចុច
- វាយតាមលំដាប់នៃការសរសេរ

  េ + រ + ៀ + ន -> រៀន







ស + ◌្ + រ + ◌ែ -> ស្រែ

ស + ◌្ + ត + ◌្ + រ + ◌ី -> ស្ត្រី

ែ + ជើងរខ្លី ្រ + ស -> ស្រែ

ជើងរវែង ្រ + ស + ្ត + ី -> ស្ត្រី

# ពុម្ពអក្សរយូនីកូដខ្មែរ

- ពុម្ពអក្សរយូនីកូដខ្មែរ Khmer OS / KhmerOS System
- ពុម្ពអក្សរយូនីកូដខ្មែរ KhmerOS Battambang
- ពុម្ពអក្សរយូនីកូដខ្មែរ KhmerOS Bokor
- ពុម្ពអក្សរយូនីកូដខ្មែរ KhmerOS Fasthand
- ពុម្ពអក្សរយូនីកូដខ្មែរ KhmerOS Freehand
- ពុម្ពអក្សរយូនីកូដខ្មែរ KhmerOS Metal Chrieng
- ពុម្ពអក្សរយូនីកូដខ្មែរ KhmerOS Muol
- ពុម្ពអក្សរយូនីកូដខ្មែរ KhmerOS Muol Light
- ពុម្ពអក្សរយូនីកូដខ្មែរ KhmerOS Muol Pali
- ពុម្ពអក្សរយូនីកូដខ្មែរ KhmerOS Siem Reap

# មុខងារគ្រាប់ចុច

- គ្រាប់ចុច ***ចន្លោះមិនឃើញ (Spacebar)*** ៖ សម្រាប់ខណ្ឌចែកពាក្យ ។
- គ្រាប់ចុច ***ប្តូរ + ចន្លោះមិនឃើញ (Shift + Spacebar)*** ៖ សម្រាប់ដកឃ្លាម្តង មួយតួអក្សរ ។
- គ្រាប់ចុច ***ឆ្លាស់ + ចន្លោះមិនឃើញ (Alt Gr + Spacebar)*** ៖ (ចន្លោះភ្ជាប់) ប្រើ សម្រាប់ចងភ្ជាប់ពាក្យ និងសញ្ញាមួយចំនួនដូចជា ! ៖ ។ ៕ ជាដើម ។
- គ្រាប់ចុច ***បញ្ចូល (Enter)*** ៖ សម្រាប់ចុះបន្ទាត់ចូលកថាខណ្ឌថ្មី ។
- ចុចគ្រាប់ចុច ***លុបថយក្រោយ (←)*** ៖ សម្គាល់ដោយសញ្ញាព្រួញមកឆ្វេង ប្រើ សម្រាប់លុបអក្សរមកឆ្វេងម្តង ១ តួអក្សរ ។
- ចុចគ្រាប់ចុច ***លុប (Delete)*** ៖ សម្រាប់លុបទៅមុខ ឬទៅស្តាំម្តង ១ តួអក្សរ ។

# ទីតាំងអក្សរខ្មែរលើគ្រាប់ចុច

**ឧទាហរណ៍ ៖** ទីតាំងអក្សរខ្មែរលើគ្រាប់ចុច *R*

ដើម្បីវាយអក្សរ **ឫ** ចុចគ្រាប់ចុច *ប្តូរ (Shift)+R*




- ដើម្បីវាយអក្សរ **រ** ចុចគ្រាប់ចុច *R*

ដើម្បីវាយអក្សរ **ឬ** ចុចគ្រាប់ចុច *ឆ្លាស់ (Alt Gr)+R*

# ចន្លោះមិនឃើញ

- ប្រើសម្រាប់ខណ្ឌចែកពាក្យ និងដើម្បីឲ្យកុំព្យូទ័រអាចពិនិត្យពាក្យខុសត្រូវបាន ។
- ត្រូវវាយបន្ទាប់ពីពាក្យនីមួយៗ




- កុំវាយចន្លោះមិនឃើញនៅចន្លោះពាក្យ **សាលា** និង **រៀន** ព្រោះសាលារៀនគឺជា **ពាក្យតែមួយ**
- ដូចគ្នាដែរ សម្រាប់ពាក្យមួយចំនួនដូចខាងក្រោម ៖

*ទ្រង់ទ្រាយ ដំណើរការ ស្រាវជ្រាវ ការងារ ទាក់ទង ត្រឹមត្រូវ...*

# ចន្លោះភ្ជាប់

- ប្រើសម្រាប់ភ្ជាប់ពាក្យ
- គួរវាយពីមុខសញ្ញា ។ ៖ !
- វាយដោយចុចគ្រាប់ចុច *ឆ្លាស់ + ចន្លោះមិនឃើញ (Alt Gr+Spacebar)*



# រៀនវាយព្យញ្ជនៈ

ចុចគ្រាប់ចុច ***ប្តូរ + ចន្លោះមិនឃើញ*** ដើម្បីដកឃ្លា

ចុចគ្រាប់ចុច ***បញ្ចូល*** ដើម្បីចុះបន្ទាត់ចូលកថាខណ្ឌថ្មី

ក ខ គ ឃ ង

ច ឆ ជ ឈ ញ

ដ ឋ ឌ ឍ ណ

ត ថ ទ ធ ន

ប ផ ព ភ ម

យ រ ល វ ស

ហ ឡ អ

# រៀនវាយស្រៈនិស្ស័យ

វាយ ***ដកឃ្លា*** មួយជាមុនសិន
រួចសូមចាប់ផ្តើមវាយស្រៈ

◌ា ◌ិ ◌ី ◌ឹ ◌ឺ

◌ុ ◌ូ ◌ួ ◌ើ ◌ឿ ◌ៀ

◌េ ◌ែ ◌ៃ ◌ោ ◌ៅ

◌ុំ ◌ំ ◌ាំ ◌ះ ◌ុះ ◌េះ ◌ោះ

ចំណាំ ៖ សូមវាយដកឃ្លាចន្លោះស្រៈនីមួយៗ ផង ។

# វាយស្រៈពេញតួ និងសញ្ញា

ឥ ឦ ឧ ឩ ឪ ឰ ឫ ឬ ឭ ឮ ឯ ឱ ឲ ឳ

◌៌ ◌៍ ◌់ ◌៏ ◌៊ ◌៎

◌៑ ◌៉

ៗ ៖ ៘ ◌ះ

( ) ៕ ៛ $ !

# របៀបវាយព្យញ្ជនៈផ្សំជាមួយស្រៈ

- វាយតាមលំដាប់ប្រកប ។

*ស + ា+ ល + ា -> សាលា*

*ទ + ៅ -> ទៅ*

- ស្រៈត្រូវវាយបន្ទាប់ពីព្យញ្ជនៈ ។

*ល + ើ -> លើ*

*ក + ុំ -> កុំ*

**វាយពាក្យទាំងនេះ ៖** *សាលារៀន ទាំងអស់ បាយ ហូប ញញួរ នោះ*

# របៀបវាយជើងព្យញ្ជនៈ




← សញ្ញាសម្រាប់ដាក់ជើង

- ដើម្បីវាយជើងព្យញ្ជនៈ ជាដំបូងអ្នកត្រូវចុចគ្រាប់ចុច សញ្ញាសម្រាប់ដាក់ជើង (◌្) បន្ទាប់មកចុចព្យញ្ជនៈដែលអ្នកចង់បាន ។

◌្ + ក -> ◌្ក

◌្ + ត -> ◌្ត

◌្ + ដ -> ◌្ដ

◌្ + ង -> ◌្ង

◌្ + រ -> ◌្រ

◌្ + ញ -> ◌្ញ

# របៀបវាយជើងព្យញ្ជនៈ ( ត )

- ត្រូវតែវាយបន្ទាប់ពីព្យញ្ជនៈ ។

ក + ◌្ + ក -> ក្ក　　　　ក + ◌្ + គ -> ក្គ

- ត្រូវតែវាយមុនស្រៈ ។

យ + ◌្ + ល + ◌ី -> យ្លី

ថ + ◌្ + ល + ◌ា -> ថ្លា

ស + ◌្ + រ + ◌ី -> ស្រី

ក + ◌្ + ល + ◌ើ -> ក្លើ

# របៀបវាយជើងព្យញ្ជនៈ ( ឥ )

ស + ្ + រ + ី -> ស្រី

ប + ្ + ដ + ី -> ប្ដី

- កុំវាយ ស + ី + ្ + រ
- កុំវាយ ប + ្ + ត + ី

## វាយពាក្យទាំងនេះ ៖

ទីផ្សារ ប្រាសាទ សម្រេច ថ្លុក ថ្លើម ប្រាង្គ

សេចក្ដី ផ្ដិល ផ្ដល់ ក្នុង ទ្រឹស្ដី

# របៀបវាយជើងព្យញ្ជនៈ ( ត )

ខ + ្ + ញ + ុំ -> ខ្ញុំ

ស + ញ + ្ + ញ + ា -> សញ្ញា

- ្រ ត្រូវតែវាយក្រោយជើងណាណាទាំងអស់ ក្នុងករណីមានជើងព្យញ្ជនៈពីរដែលមានមួយជា ្រ ។

ស + ្ + ត + ្ + រ + ី -> ស្ត្រី

ស + ង + ្ + គ + ្ + រ + ុ + ប -> សង្គ្រុប

# ត្រីសព្ទ( ៊ ) ឬមូសិកទន្ត( ៉ )

- កុំវាយ ុ ជំនួសឲ្យ ៊ ឬ ៉ ។

*ស + ៊ + ី -> ស៊ី* **កុំវាយ** *ស + ី + ុ*

*ប + ៉ + ី -> ប៉ី* **កុំវាយ** *ប + ី + ុ*

វាយពាក្យទាំងនេះ ៖

*កុងស៊ី តឹងរ៉ឹង នាម៉ឺន ប៉ីតប៉ោង ប៊ីជុង ម៉ាស៊ីន*

*រប៉ិលរប៉ូច កំប៉ិកកំប៉ុក ប៉ប៉ិលប៉ប៉ូច*

# ត្រីសព្ទ( ៊ ) ឬមូសិកទន្ត( ៉ ) (ត)

- វាយបន្ទាប់ពីជើង និងមុនស្រះ ។

ស + ្ + រ + ៊ + ុ + ប -> ស្រ៊ុប

វាយពាក្យទាំងនេះ ៖

ម្ល៊ឹង បន្ស៊ុ ស្ល៊ុកគ្រោក

# សញ្ញាលើ

សញ្ញាលើមានដូចជា ៖ ◌៌ ◌៍ ◌៎ ◌៏ ◌័ ◌់

- វាយបន្ទាប់ពីព្យញ្ជនៈ ដែលវានឹងនៅពីលើ ។

ទ + ◌ំ + ព + ◌័ + រ -> ទំព័រ ព + ណ + ◌៌ -> ពណ៌

**ចំណាំ ៖** ◌ិ + ◌៍ -> ◌ិ◌៍

វាយពាក្យទាំងនេះ ៖

*ទុគ៌ត ទុឃ៌ស បរិបូណ៌ លោមព័ណ៌ ព័ត៌មាន*

*យុត្តិធម៌ សម្បូណ៌ ពោធិ៍ ប្រាក់ ស៊ីម៉ងត៍ ប៉ុងតោ*

# សញ្ញាលើ ( ត )

- វាយមុនស្រះ ។

ក + ប + ៌ + ូ + រ -> កប៌ូរ

ម + ា + គ + ៌ + ា -> មាគ៌ា

វាយពាក្យទាំងនេះ ៖

សព៌េជ្ញ អជ៌ុន កាប៌ាស

# អនុវត្ត

*សូមវាយអត្ថបទឲ្យដូចខាងក្រោមនេះ ៖*

ឆ្មាចូលចិត្តស៊ីត្រី ។

ខ្ញុំជាស្ត្រីខ្មែរ ចូលចិត្តញ៉ាំបាយទៀងពេល ។

កម្ពុជាជាប្រទេស ដែលសម្បូរទៅដោយសម្បត្តិវប្បធម៌ អរិយធម៌ និងធនធានធម្មជាតិ ព្រមទាំងមានប្រាង្គប្រាសាទជាច្រើន ។